# ឯកសារទស្សនទាន
# វេទិកាសិក្សារៀនសូត្រការគ្រប់គ្រងធនធានមនុស្សលើកទី៣៧

## ស្តីពី

## " ការរំសាយនិងកាត់បន្ថយបុគ្គលិក"

ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៨ វេលាម៉ោង៨: 00នាទី ព្រឹកដល់ម៉ោង៥:០០នាទីរសៀល
នៅជាយកូនៀសិនធើ ផ្ទះលេខ១៩-២១ផ្លូវលេខ៣៣០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ

## I.សេចក្តីផ្តើម

អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជាហៅកាត់ថា (គ.ស.ក) គឺជាអង្គការសមាជិកភាពដែលបានបង្កើតឡើងដំបូងគេបង្អស់នៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៩០ ដោយបានដើរតួនាទីចំបងក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ វិជ្ជាជីវៈ គណនេយ្យភាព តម្លាភាព អភិបាលកិច្ច និងការអភិវឌ្ឍ ប្រកបដោយប្រសិទ្ធភាពចំពោះអង្គការសង្គមស៊ីវិលដែលកំពុងប្រតិបត្តិការវិស័យផ្សេងៗគ្នានៅក្នុងប្រទេសកម្ពុជា។

នៅក្នុងដំណាក់កាលទី៣នៃផែនការកម្មវិធីរបស់អង្គការ គ.ស.ក សម្រាប់រយៈពេលប្រាំឆ្នាំ២០១៧ដល់២០២១។ គោលដៅអង្គការគ.ស.កគឺជាអង្គការសង្គមស៊ីវិលមួយដែលមានកិច្ចសហការដ៏រឹងមាំ និងមានសមត្ថភាពឆ្លើយតបទៅនឹងបញ្ហានៃការអភិវឌ្ឍនៅកម្ពុជា។ គោលដៅផែនការកម្មវិធីគឺ: ១) បង្កើនប្រសិទ្ធភាពនិងផលប៉ះពាល់នៃអង្គការសង្គមស៊ីវិល និង ២)ធ្វើឲ្យប្រសើរឡើងនូវបរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិល។ ដើម្បីឆ្លើយតបទៅនឹងគោលដៅរបស់ខ្លួន អង្គការ គ.ស.ក បានរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាព និងឪកាសសិក្សារៀនសូត្រសម្រាប់បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ដើម្បីមានឥទ្ធិពលដល់ការគិត និងការអនុវត្តន៍របស់ពួកគេ និងដើម្បីផ្តល់សេវាកម្មដែលមានគុណភាពខ្ពស់សមស្របក្នុងការឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៃអង្គការសង្គមស៊ីវិលទាំងនោះ។

យុទ្ធសាស្រ្តមួយក្នុងចំណោមយុទ្ធសាស្រ្តទាំងប្រាំពីរគឺ ការសិក្សារៀនសូត្រនិងអភិវឌ្ឍន៍សមត្ថភាពសម្រាប់សមាជិករបស់អង្គការគសក និង អង្គការសង្គមស៊ីវិលផ្សេងៗទៀតដែលបានចាប់អារម្មណ៍។ ក្នុងចំណោម កម្មវិធីនេះគឺ វេទិកាសិក្សារៀនសូត្រអំពី ការគ្រប់គ្រងធនធានមនុស្ស ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ព័ត៌មានទំនាក់ទំនងបច្ចេកវិទ្យា និង ការគ្រប់គ្រងហិរញ្ញវត្ថុ ។ វេទិកាសិក្សារៀនសូត្រនេះមានសារៈសំខាន់ណាស់ក្នុងការកសាងសមត្ថភាពសមាជិករបស់ខ្លួនដើម្បីឲ្យការអនុវត្តន៍ផ្តល់សេវាកម្មរបស់ពួកគេកាន់តែប្រសើរឡើង។

ដើម្បីធានាបាននូវគុណភាពនៃវេទិកាសិក្សារៀនសូត្រនេះ អង្គការគសកបានបង្កើតក្រុមការងារដើម្បី



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street. 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

Accountability
GPP
Symbol of Trust

ជួយផ្តល់ការពិភាក្សានិងយោបល់សម្រាប់ការសិក្សារៀនសូត្ររបស់អង្គការសហគមន៍នៅក្នុងប្រទេសកម្ពុជា។ ក្រុមការងារនេះបានដើរតួនាទីគណៈកម្មការទទួលខុសត្រូវរួមដើម្បីផ្តល់ជាយុទ្ធសាស្ត្រ និងបច្ចេកទេសគាំទ្រដល់អង្គការសហគមន៍ក្នុងការលើកកំពស់និងធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រងធនធានមនុស្ស ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ព័ត៌មានទំនាក់ទំនងបច្ចេកវិទ្យា និង ការគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងអង្គការរបស់ពួកគេសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផលក្នុងវិស័យអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា។

ដើម្បីបន្តការឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់អង្គការសហគមន៍និងពង្រឹងសមត្ថភាពបន្ថែមអំពីអភិបាលកិច្ចល្អនៅក្នុងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា អង្គការគសកនឹងត្រូវបានអនុវត្តបន្តវេទិកាសិក្សារៀនសូត្រលើកទី៣៧នៃការគ្រប់គ្រងធនធានមនុស្សដោយផ្អែកលើប្រធានបទដែលបានជ្រើសរើសដោយក្រុមការងារនិងផ្អែកលើតម្រូវការច្បាប់នៃប្រទេសកម្ពុជា។

វេទិកាសិក្សារៀនសូត្រលើកទី៣៧នៃការគ្រប់គ្រងធនធានមនុស្សគឺត្រូវបានកំណត់អ្នកចូលរួមជំនាញគ្រប់គ្រងធនធានមនុស្សដែលអញ្ជើញមកពីអង្គការសមាជិក និងមិនមែនសមាជិករបស់អង្គការគសក។ វេទិកានេះនិងប្រារព្វឡើងពេញមួយថ្ងៃនៅថ្ងៃទី**៥ខែកញ្ញាឆ្នាំ២០១៨ នៅអាគារដាយកូនៀសិនធើ ដែលមានគោលបំណងជាក់លាក់ លទ្ធផលរំពឹងទុករយៈពេលមធ្យម និងកម្មវិធីលំអិតដូចខាងក្រោមនេះ៖**

## II. កាលបរិច្ឆេទនិងទីកន្លែងនៃវេទិកាសិក្សារៀនសូត្រ

វេទិកានេះនឹងប្រារព្ធធ្វើឡើងពេញមួយថ្ងៃនៅថ្ងៃទី**៥ខែកញ្ញាឆ្នាំ២០១៨** **វេលាម៉ោង៨: 00នាទី ព្រឹកដល់ម៉ោង៥:00នាទី**រសៀលនៅដាយកូនៀសិនធើ ផ្ទះលេខ១៩-២១ផ្លូវលេខ៣៣០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ។

## III. គោលបំណងនៃវេទិកាសិក្សារៀនសូត្រ

- ដើម្បីរំលឹកមេរៀនពីមុនឡើងវិញក្នុងការជួយឲ្យសិក្ខាកាមកាន់តែយល់អំពីការអនុវត្តច្បាប់ការងារស្តីពី របបសន្តិសុខសង្គម និងសៀវភៅការងារកាតព្វកិច្ចនៃការអនុវត្តច្បាប់ធានារ៉ាប់រងផ្នែកហានិភ័យការងារ ផ្នែកថៃទាំសុខភាព និងផ្នែកប្រាក់សោធនសម្រាប់អង្គការសង្គមស៊ីវិល
- ដើម្បីលើកកម្ពស់សិក្ខាកាមយល់ច្បាស់អំពីនិតិវិធីកាត់រំសាយបុគ្គលិកប្រកបដោយប្រសិទ្ធភាព
- ដើម្បីបង្កើតបរិយាកាសវេទិការៀនសូត្រ ចែករំលែកនិងការកសាងបណ្តាញឲ្យកាន់តែមានភាពរឹងមាំ

## IV. លទ្ធផលរំពឹងទុករយៈពេលមធ្យម

- សិក្ខាកាមនឹងកាន់តែយល់ច្បាស់អំពីការអនុវត្តច្បាប់ការងារទាក់ទងនិងនិតិវិធី របបសន្តិសុខសង្គមនិងសៀវភៅការងារ កាតព្វកិច្ចនៃការអនុវត្តច្បាប់ធានារ៉ាប់រងផ្នែកហានិភ័យការងារ ផ្នែកថៃទាំសុខភាពនិងផ្នែកប្រាក់សោធនសម្រាប់អង្គការសង្គមស៊ីវិល
- សិក្ខាកាមនឹងកាន់តែយល់ច្បាស់ពីនិតិវិធីរំសាយនិងកាត់បុគ្គលិកប្រកបដោយប្រសិទ្ធភាព
- សិក្ខាកាមនឹងមានឪកាសច្រើនក្នុងការរៀនសូត្រ ការចែករំលែក និងការទំនាក់ទំនង និងការចងបណ្តាញកាន់តែប្រសើរឡើង។

## V. សិក្ខាកាមគោលដៅ

វេទិកាសិក្សារៀនសូត្រនេះនឹងផ្តល់ជូនសិក្ខាកាមអបប្បរមា៨០ទៅ១០០នាក់ដែលអញ្ជើញមកពីសមាជិក និងមិនមែនជាសមាជិករបស់អង្គការគសកដែលមានវិជ្ជាជីវៈផ្នែកផ្នែកគ្រប់គ្រងធនធានមនុស្ស។ សិក្ខាកាមម្នាក់ៗ គួរត្រូវបានកំណត់កម្រិតបុគ្គលិកថ្នាក់គ្រប់គ្រងជាន់ខ្ពស់ និងថ្នាក់គ្រប់គ្រងកណ្តាលរបស់អង្គការ ហើយពួកគេនឹងមានការប្តេជ្ញាចិត្តយកទៅអនុវត្តន៍នូវអ្វីដែលបានរៀននៅក្នុងអង្គការរបស់ពួកគេ។

សូមស្វាគមន៍សិក្ខាកាមដែលអញ្ជើញមកពីអង្គការមិនមែនសមាជិករបស់អង្គការគសក ប៉ុន្តែតម្រូវឲ្យចូលរួមបង់វិភាគទានទៅតាមគោលការណ៍ដែលបានចែងនៅក្នុងគោលនយោបាយសេវាកម្មអភិវឌ្ឍសមត្ថភាព ដើម្បីយកទៅជួយគាំទ្រផ្នែករៀបចំភស្តុភា។

## VI. កម្មវិធីលម្អិត

| ពេលវេលា | មាតិកាសំខាន់ៗ | វាគ្មិនដោយ |
|---|---|---|
| 07:30-08:20 | ចុះបញ្ជីវត្តមាន | • **អ្នកស្រី ស្រេង សោភ័ណលក្ខិណា**<br>ជំនួយការផ្នែកកម្មវិធី<br>អង្គការគសក |
| 08:20-08:30 | គោរពទង់ជាតិ | • **អង្គសិក្ខាកាម** |
| | កិច្ចស្វាគមន៍<br>ការណែនាំអំពីគោលបំណងនៃវេទិកាសិក្សារៀនសូត្រ និងការប្រកាសជូនដំណឹងទូទៅ | • **អ្នកស្រី កែវ ម៉ារ៉ា**<br>អ្នកឯកទេសផ្នែកសិក្សារៀនសូត្រ<br>អង្គការគសក |
| 08:30-08: 35 | កិច្ចស្វាគមន៍ និង សន្ទរកថាបើកកម្មវិធី | • **លោក យន ប៊ុនថុង**<br>ប្រធានផ្នែកប្រតិបត្តិការ<br>អង្គការគសក |
| 08:35-09:20 | <u>វគ្គទី១:</u> រំលឹកមេរៀនឡើងវិញស្តីពី "**<u>ការអនុវត្តច្បាប់ការងារ" ស្តីពី បណ្ណ/សៀវភៅការងារ និងបេឡាជាតិរបបសន្តិសុខសង្គម</u>**<br>• សេចក្តីណែនាំអំពីការស្នើសុំបណ្ណ/សៀវភៅការងារ<br>• បេឡាជាតិរបបសន្តិសុខសង្គម | • **អ្នកស្រី សឿង សត្យា**<br>អ្នកឯកទេសគ្រប់គ្រងធនធានមនុស្ស<br>អង្គការគសក |
| 09:20:- 09:45 | **<u>វគ្គទី២:</u>** បទបង្ហាញស្តីពីៈ<br>• សេចក្តីណែនាំនិងរូបភាពរួមនៃការរំសាយនិងកាត់បន្ថយបុគ្គលិក<br>• **សំណួរនិងចម្លើយ** | • **លោក សេង សារុធ**<br>**នាយករងគ្រប់គ្រងទូទៅ**<br>V CHARTERED ACCOUNTANTS CO., LTD |
| 9:45:- 10:00 | **សម្រាកពិសារអាហារសម្រន់** | All |
| 10:00-11:00 | **<u>វគ្គទី៣: ការពិភាក្សាក្រុមនិងការចែករំលែកបទពិសោធន៍</u>** | • **លោក ឡាយ ឈុន** |



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
#9-11, Street. 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

| | | |
|---|---|---|
| | • ការរំសាយនិងកាត់បន្ថយបុគ្គលិក<br>• វេទិកាចែករំលែកលទ្ធផលក្រុមពិភាក្សា<br>• **សំណួរនិងចម្លើយ** | **ប្រធានគ្រប់គ្រងធនធានមនុស្ស**<br>**IDE Cambodia**<br>• **អង្គសិក្ខាកាម** |
| 11:00-12:00 | វគ្គទី៤: <u>**បទបង្ហាញនិងការចែករំលែកស្តីពី ករណីសិក្សា**</u><br>• និតិវិធី និងដំណើរការ រំសាយនិងកាត់បន្ថយបុគ្គលិក<br>• **សំណួរ និងចម្លើយ** | • **អ្នកស្រី ហេង រតនា**<br>People & Culture Technical Manager, World Vision International<br>• **លោក ភាព ម៉ូណ្ឌ**<br>HR and Administration Director PSI/C<br>• **អង្គសិក្ខាកាម** |
| 12:00-01:30 | **សម្រាកពិសារអាហារសាមគ្គី** | • **អង្គសិក្ខាកាម** |
| 01:30-01:35 | **ល្បែងថាមពល** | • **អង្គសិក្ខាកាម** |
| 01:35-03:00 | វគ្គទី៤: បទបង្ហាញ ស្តីពី<br>• សេចក្តីផ្តើម<br>• និតិវិធី និងដំណើរការ រំសាយនិងកាត់បន្ថយបុគ្គលិក<br>• គោលនយោបាយផ្ទៃក្នុង<br>• សំណួរ និងចម្លើយ | • **លោក ឡាយ ឈុន**<br>ប្រធានគ្រប់គ្រងធនធានមនុស្ស<br>IDE Cambodia<br>• **អង្គសិក្ខាកាម** |
| 3:00-3:15 | **សម្រាកពិសារអាហារសម្រន់** | • **អង្គសិក្ខាកាម** |
| 3:15-4:30 | <u>**វគ្គទី៤:**</u> (ត) បទបង្ហាញបន្ត ស្តីពី<br>• គោលនយោបាយផ្ទៃក្នុង<br>• ការអនុវត្តច្បាប់ការងារ<br>• វេទិកាចែករំលែក<br>• **សំណួរ និងចម្លើយ** | • **លោក ឡាយ ឈុន**<br>ប្រធានគ្រប់គ្រងធនធានមនុស្ស<br>IDE Cambodia<br>• **អង្គសិក្ខាកាម** |
| 4:30-4:50 | <u>**វគ្គទី៥:**</u><br>• ចំណាប់អារម្មណ៍សិក្ខាកាម<br>• ការវាយតម្លៃបញ្ចប់វគ្គ | • **អ្នកស្រី កែវ ម៉ារ៉ា**<br>អ្នកឯកទេសផ្នែកសិក្សារៀនសូត្រ<br>អង្គការគសក<br>• **អង្គសិក្ខាកាម** |
| 4:50-5:00 | **សេចក្តីសនិដ្ឋានរួមនិងមតិបិទកម្មវិធី** | • **អ្នកស្រី ស៊ិន ពុទ្ធារី**<br>ប្រធានផ្នែកទំនាក់ទំនងនិង<br>អភិវឌ្ឍន៍សមាជិក<br>អង្គការគសក |

<u>សំគាល់:</u> អង្គការគសកសូមរក្សាសិទ្ធិក្នុងការកែប្រែកម្មវិធីដោយផ្អែកលើលទ្ធភាពរបស់វាគ្មិននិងបញ្ហាពេលវាលា ក្នុងករណីចាំបាច់។



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street. 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia